ព្រះវិហារកោះរំដួលបាប់ទីស្ទ

**Widow Island Baptist Church**

# ផែនការយុទ្ធសាស្ត្ររបស់ព្រះវិហារកោះរំដួលបាប់ទីស្ទ ឆ្នាំ២០២៦ ដល់ ២០២៣០

# Widow Island Baptist Church Strategy Plan 2026-2030

## I. បេសកកម្ម / Mission

ព្រះវិហារកោះរំដួលបាប់ទីស្ទជាកន្លែងបង្ហាត់បង្រៀនព្រះបន្ទូលរបស់ព្រះទៅដល់មនុស្សទាំងអស់ តាមរយៈ ការបង្កើតទំនាក់ទំនងនិងការប្រកបជិតស្និតជាមួយព្រះនិងគ្នាទៅវិញទៅមក

ដែលជាផ្លូវនាំទៅសេចក្តីសង្គ្រោះតាមរយៈសេចក្តីស្រលាញ់និងការសង្គ្រោះរបស់ព្រះយេស៊ូគ្រីស្ទ។

Widow Island Baptist Church exists to share God’s Word with all people, build deep relationships with God and one another, and be a way to salvation through the love and redeeming grace of Jesus Christ.

## II. ការវិភាគសហគមន៍ / **Contextual Analysis**

យោងតាមការវិភាគសហគមន៍នៅក្នុងតំបន់ព្រះវិហារកោះរំដួលបាប់ទីស្ទ យើងមើលឃើញការធំៗបីយ៉ាង៖

Based on the community analysis in the Widow Island Baptist Church area, we observed three main points:

1. **ការរស់នៅ៖** ប្រជាជននៅសហគមន៍នេះមានការរកស៊ីអាស្រ័យទៅនឹងផលកសិកម្ម នេសាទ ការងាររោងចក្រ និងសំណង់។ ប្រជាជនខ្វះខាតនូវការលើកទឹកចិត្តកូនឲ្យទៅរៀន និងមានការប្រើប្រាស់គ្រឿងស្រវឹងច្រើន ដែលនាំឲ្យមានការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ និងខ្វះខាតនូវទំនាក់ទំនងរវាងអ្នកភូមិរបងជាមួយគ្នា ដែលពេលខ្លះបង្ករជាជម្លោះ។ ទោះបីជាយ៉ាងណាគួរកត់សម្គាល់ឃើញថាប្តីប្រពន្ធមានការគោរពគ្នា។

   **Living conditions**: The people in this community rely on agriculture, fishing, factory work, and construction for their livelihoods. Many parents lack encouragement for their children to pursue education, and there is a high consumption of alcohol, which leads to domestic violence and weakens relationships between neighbors—sometimes causing conflicts. Nevertheless, it is noteworthy that husbands and wives generally show respect toward each other.

2. **ការអប់រំ៖** ប្រជាជននៅក្នុងសហគមន៍មិនសូវមានការយល់ដឹងពីតម្លៃនៃការអប់រំ ដោយជីវភាពឪពុកម្តាយខ្វះខាត ដូច្នេះឪពុកម្តាយសម្រេចឲ្យកុមារឈប់សិក្សាហើយជួយធ្វើការងារដើម្បីផ្គត់ផ្គង់គ្រួសារ ម្យ៉ាងវិញទៀតកម្រិតនៃការអប់រំនៅក្នុងសហគមន៍នៅមានកម្រិត។ លើសពីនោះ កុមារមានការខ្វះការយល់ដឹងនូវការថែរក្សាអនាម័យផ្ទាល់ខ្លួន និងការថែរក្សាខ្លួន។

   **Education**: People in the community generally have limited awareness of the value of education. Due to parents’ difficult living conditions, many decide to withdraw their children from school so they can work and help support the family. Moreover, the overall educational level in the community remains low. In addition, children lack awareness about personal hygiene and self-care.

3. **ជំនឿ៖** ប្រជាជនក្នុងសហគមន៍មានជំនឿលើព្រះពុទ្ធសាសនា(៤០%) គ្រីស្ទសាសនា (២០%) ជំនឿលើសាសនាចិន (២០%) ជំនឿលើអាសនៈផ្សេងៗ (១០%) ជំនឿលើខ្លួនឯង (១០%) និងមានការផ្តល់សិទ្ធស្មើរគ្នារវាងភេទទាំងពីរ។

**Belief**: The people in the community hold various beliefs—Buddhism (40%), Christianity (20%), Chinese religion (20%), other religions (10%), and self-belief (10%). There is also equal gender rights between men and women.

- **ការឆ្លើយតបរបស់ព្រះវិហារកោះរំដួលបាប់ទីស្ទលើបញ្ហានៃសហគមន៍ខាងលើ**
  **Widow Island Baptist Church Respond**

ព្រះវិហារកោះរំដួលបាប់ទីស្ទឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលសហគមន៍កំពុងជួបប្រទះ មានដូចខាងក្រោម៖

Widow Island Baptist Church responds to the challenges faced by the community as follows:

1. **ការឆ្លើយតបលើការរស់នៅ៖** ព្រះវិហារនឹងមានគម្រោងកម្មវិធីលើការយកចិត្តទុកដាក់ចំពោះកុមារ និងបញ្ជ្រៀបនូវសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវគ្រីស្ទទៅកាន់ឳពុកម្តាយតាមរយៈការចុះសួរសុខទុក្ខ និងការបង្កើតទំនាក់ទំនង និងធ្វើការអញ្ជើញពួកគេចូលរួមក្នុងសកម្មភាពព្រះវិហារ។

   **Response to living conditions**: The church will implement programs focusing on caring for children and sharing the love of Jesus Christ with parents through home visits, relationship building, and inviting them to participate in church activities.

2. **ការឆ្លើយតបទៅនឹងការអប់រំ៖** ព្រះវិហាររៀបចំកម្មវិធីជម្រុញការសិក្សារបស់កុមារ និងការលើកទឹកចិត្ត និងផ្សព្វផ្សាយអំពីការអប់រំវិជ្ជមានទៅកាន់អាណាព្យាបាលឲ្យយល់ដឹងពីតម្លៃនៃការសិក្សា និងឧបត្ថម្ភលើកាសិក្សារបស់កុមារ និងបង្រៀនពីការរស់នៅដោយអនាម័យចំពោះកុមារ។

   **Response to education**: The church organizes programs to encourage children's learning, raise awareness among parents and guardians about the value of education, provide support for children's educational opportunities, and teach children about living with good hygiene.

3. **ការឆ្លើយតបទៅនឹងជំនឿ៖** ព្រះវិហារនឹងធ្វើការបង្កើតទំនាក់ទំនងយ៉ាងជិតស្និតក្នុងសហគមន៍ ហើយផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូទៅកាន់មនុស្សទាំងអស់ តាមរយៈការចុះសួរសុខទុក្ខ អធិស្ឋាន។

   **Response to belief**: The church will build close relationships within the community and share the Good News of Jesus with everyone through home visits and prayer.

## III. អំពីព្រះវិហារកោះរំដួលបាប់ទីស្ទ / About Widow Island Baptist Church

តាមរយៈការឆ្លុះបញ្ចាំងជាមួយគ្នា យើងមើលឃើញព្រះវិហារមានការកត់សម្គាល់៤ចំណុច៖

Through reflection together, we observed that the church has identified four key points:

1. **ភាពខ្លាំង៖** ព្រះវិហារមានភាពខ្លាំងលើភាពឆេះឆួលនៃការផ្សាយដំណឹងល្អ ចុះទៅតាមភូមិគោលដៅ មានការចូលរួមពីយុវជន កុមារ និងមនុស្សចាស់ មានការចុះសួរសុខទុក្ខ មានយុវជនជួយបង្រៀនកុមារ មានគ្រូបង្គោល គ្រូជំនួយ និងមានការស្ម័គ្រចិត្តរបស់សមាជិកក្នុងការជួយលើព័ន្ធកិច្ចយុវជន ស្ត្រី និងមានថ្នាក់របាំ និងសមាជិកមានការចូលរួមថ្វាយបង្គំព្រះទៀងទាត់ និងសមាជិកមានការកើនឡើង។

   **Strengths**: The church is strong in its passion for spreading the Good News, reaching out to target villages, and engaging youth, children, and the elderly. It conducts home visits, with youth helping to teach children, having pastor and pastor assistant. Members volunteer actively in youth and women's programs, regularly attend worship services, and overall, church membership is increasing.

2. **ភាពខ្សោយ៖** ព្រះវិហារមានភាពខ្សោយលើការមិនទាន់បែងចែកកុមារថ្នាក់ថ្ងៃអាទិត្យទៅតាមអាយុ ខ្វះខាតសម្ភារៈបង្រៀនកុមារ ត្រូវការគ្រូជំនួយបង្រៀននៅសហគមន៍ផ្សាយដំណឹងល្អនៅភូមិព្រែកត្រែង កុមារមកចូលរួមកម្មវិធីមិនទៀងទាត់ មិនមានថវិកាសម្រាប់ការប្រកបគ្រប់គ្រាន់ និងដំណើរកំសាន្តប្រចាំឆ្នាំ ខ្វះខាតនូវឧបករណ៍ភ្លេង មិនទាន់មានកម្មពិធីសព។

   **Weaknesses**: The church is weak in not yet dividing Sunday school children by age groups, lacking teaching materials for children, needing assistant teachers in the outreach community for evangelism in Prek Trang village, irregular participation of children in programs, insufficient budget for regular operations and annual trips, lack of musical instruments, and the absence of programs for funerals.

3. **ហានិភ័យ៖** ព្រះវិហារមានហានិភ័យ ដោយមិនមានជំនួយថវិកាច្បាស់លាស់សម្រាប់ផ្គត់ផ្គង់កម្មវិធីព្រះវិហារ និងការផ្សាយដំណឹងល្អ ឬតម្រូវការដែលព្រះវិហារត្រូវការ។ ចំពោះសមាជិកមានវ័យចាស់និងមានជម្ងឺឈឺរ៉ាំរ៉ៃ។

   **Risks**: The church faces risks due to the lack of budget to support its programs and evangelism, or to meet the church's needs. Additionally, some members are elderly and suffer from chronic illnesses.

4. **ឱកាស៖** ព្រះវិហារមានឱកាសឈោងចាប់តំបន់ផ្សាយដំណឹងល្អផ្សេងទៀតដែលមិនទាន់លឺពីដំណឹងល្អអំពីព្រះយេស៊ូគ្រីស្ទ គម្រោងឧបត្ថម្ភកាសិក្សាទៅដល់សិស្សានុសិស្សក្នុងសហគមន៍ យុវជនបញ្ចប់ការសិក្សាអាចមានលទ្ធភាពបន្តរកាសិក្សានៅសាកលវិទ្យាល័យតាមរយៈអាហារូបករណ៍របស់ព្រះវិហារ ការបង្កើតសិស្សមួយទល់នឹងមួយ មានថ្នាក់បង្រៀនព្រះគម្ពីរក្នុងសហគមន៍ ពង្រឹងវិស័យកីឡាទៅដល់យុវជនប្រុសស្រី លើសពីនោះការមានស័យនដ្ឋានសម្រាប់និស្សិតនៅឯក្រុងតាខ្មៅ។

   **Opportunities**: The church has opportunities to reach other areas where people have not yet heard the Good News of Jesus Christ. It can implement scholarship programs for students in the community, allowing youth who have completed their studies to potentially continue to university through church-provided scholarships. The church can also make disciple via one on one study program, offer Bible teaching classes within the community, strengthen sports programs for both boys and girls, and provide dormitory facilities for students in Ta Khmao city.

## IV. ទស្សនៈវិស័យ / Vision

ព្រះវិហារកោះរំដួលបាប់ទីស្ទមានការរីកចម្រើនក្នុងព្រះបន្ទូលព្រះ ដោយមានអ្នកបំរើខ្ជាប់ខ្ជួនក្នុងសេចក្ដីជំនឿរឹងមាំក្នុងព្រះអម្ចាស់ មានការរួបរួមក្នុងសេចក្ដីស្រលាញ់ បំរើគ្នាទៅវិញទៅមក និងនាំយកសេចក្ដីសង្ឃឹមទៅកាន់សហគមន៍តាមរយៈសេចក្ដីស្រលាញ់របស់ព្រះយេស៊ូគ្រីស្ទ។

Widow Island Baptist Church is to grow in God's Word, with devoted servants steadfast in faith, united in love, serving one another, and bringing the hope of Jesus Christ to the community.

## V. គុណតម្លៃ / Core Value

ព្រះវិហារកោះរំដួលបាប់ទីស្ទមានគុណតម្លៃស្នូលចំនួន៤ ចំណុច៖

Widow Island Baptist Church has 4 core value:

1. **សេចក្តីស្រលាញ់**/ □□□□

យើងផ្តល់សេចក្តីស្រលាញ់តាមរយៈការចុះសួរសុខទុក្ខ មានទំនាក់ទំនងល្អ ចែករំលែកនូវអ្វីដែលយើងមាន និងការប្រើអាកប្បកិរិយាល្អ សម្តីសមរម្យចំពោះមនុស្សទាំងអស់ ដោយសេចក្តីស្រលាញ់របស់ព្រះយេស៊ូគ្រីស្ទជាគំរូ។

We demonstrate love by visiting and caring for others, fostering good relationships, sharing what we have, and showing kindness in our actions and words to everyone — following the example of the love of Jesus Christ.

2. **បង្កើតសិស្ស**/ □□□□ □□□□□□□□□□

ដោយអនុវត្តតាមគំរូរបស់ព្រះយេស៊ូគ្រីស្ទ យើងបង្ហាត់បង្រៀន បណ្តុះបណ្តាល និងបង្ហាញគំរូរបស់ទ្រង់ដើម្បីឲ្យមនុស្សជាច្រើនក្លាយជាសិស្សរបស់ទ្រង់និងរីកចម្រើនក្នុងសេចក្តីជំនឿ។

Following the example of Jesus Christ, we teach, train, and model His ways so that many people will become His disciples and grow in faith.

3. **ផ្សាយដំណឹងល្អ**/ □□□□□□□□ □□□ □□□□□□□

យើងជឿជាក់ថាការផ្សាយដំណឹងល្អគឺជាព្រះឬទ័យរបស់ព្រះសម្រាប់មនុស្សទាំងអស់ ដូច្នេះ យើងផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រីស្ទ និងនាំមនុស្សឲ្យមានទំនាក់ទំនងជាមួយទ្រង់ និងទទួលបានសេចក្តីសង្គ្រោះ។

We believe that sharing the good news is at the heart of God’s desire for all people. Therefore, we proclaim the Gospel of Jesus Christ, leading others into a relationship with Him and the gift of salvation.

4. **ផ្តល់តម្លៃ**/ □□□□□□ □□□□□□□

យើងជឿថាមនុស្សគ្រប់រូបមានតម្លៃស្មើរៗគ្នា ដូច្នេះយើងរួមគ្នាគោរព និងផ្តល់តម្លៃឲ្យគ្នាទៅវិញទៅមក ដូចជាព្រះបានផ្តល់តម្លៃដល់មនុស្សគ្រប់គ្នា។

We believe that every person is equally precious, and we honor and respect one another, following God’s example of valuing all people.

## VI. គោលដៅ / Goal

ព្រះវិហារមានផែនការយុទ្ធសាស្ត្រសម្រាប់ ៥ ឆ្នាំ គឺពីឆ្នាំ ២០២៦ ដល់ ២០៣០ ដោយផ្តោតលើគោលដៅ ក្រុមយុវជន កុមារ ក្រុមស្ត្រី ក្រុមបុរស ការផ្សាយដំណឹងល្អនិងការថ្វាយបង្គំព្រះ។

The church has a five-year strategic plan from 2026 to 2030, focusing on youth groups, children, women's groups, men's groups, evangelism, and worship services.

| គោលដៅ/ Goal | ការតម្រង់ទិស/ Guideline | រយៈពេល/ Time |
|---|---|---|
| ពង្រឹងសេចក្តីជំនឿរបស់កុមារ (៧០ នាក់)<br>Strengthen the faith of children (70 children) | 1. បង្កើតថ្នាក់រៀនថ្ងៃអាទិត្យទៀងទាត់៖ រៀបចំថ្នាក់បង្រៀនព្រះគម្ពីរតាមអាយុរៀងរាល់សប្តាហ៍ ដើម្បីបង្រៀនអំពីជំនឿគ្រឹះមូលដ្ឋាន។<br>Regular Sunday School – Hold age-appropriate Bible classes every week to teach foundational Christian beliefs.<br>2. ការរៀនព្រះបន្ទូលផ្សំជាមួយសកម្មភាព៖ និទានរឿង ឬប្រើវីឌីអូ បទចម្រៀង ល្បែង ការប្រើប្រាស់សិប្បកម្ម ដើម្បីឲ្យការសិក្សាអំពីជំនឿមានភាពរីករាយ។<br>Interactive Learning – Use stories, songs, games, and crafts to make learning about faith engaging.<br>3. បណ្តុះបណ្តាលគ្រូ៖ ជ្រើសរើសគ្រូបង្រៀន ២-៣ នាក់និងផ្តល់ការហ្វឹកហ្វឺនដឹកនាំថ្នាក់ថ្ងៃអាទិត្យ។<br>Teacher Training: Select 2–3 teachers and provide training for leading Sunday school classes.<br>4. បង្កើតសាលារាំកង៖ ផ្តល់ការជួបជុំការរៀនចំពោះកុមារមួយឆ្នាំមួយដង<br>Create Vacation Bible study: Organize a learning and fellowship program for children once a year.<br>5. ការបោះជំរុំកុមារ៖ បង្កើតការបោះជំរុំកុមារមួយឆ្នាំមួយដង<br>Children's Camp: Organize a children's camp once a year. | មករា ២០២៦ - ធ្នូ ២០៣០<br>Jan 2026- Dec 2030 |
| ពង្រឹងព័ន្ធកិច្ចយុវជន (៤០ នាក់)<br>Strengthen the faith of youth (40 youths) | 1. ជ្រើសរើសនិងបណ្តុះបណ្តាលគ្រូដឹកនាំយុវជន ១-២ នាក់<br>Select and Train Youth Leaders: Choose 1–2 youth leaders and provide training for them.<br>2. ប្រកបជាមួយយុវជនមួយខែ១ម្តង<br>Monthly Youth Fellowship: Hold a gathering with youth once a month. | មករា ២០២៦ - សីហា ២០៣០<br>Jan 2026- Aug 2030 |

| | | |
|---|---|---|
| | 3. ការជួបជុំថ្វាយបង្គំនិងរៀនព្រះបន្ទូលព្រះនៅរៀងរាល់ថ្ងៃសៅរ៍ ពីម៉ោង 6:00-7:00 ល្ងាច<br>Weekly Worship and Bible Study: Hold worship and Bible study every Saturday from 6:00 to 7:00 PM.<br>4. ការហាត់សមកីឡាបាល់ទាត់សម្រាប់យុវជនបុរស និងយុវជនស្ត្រីរៀងរាល់ថ្ងៃសៅរ៍ និងការប្រកួតពានមួយឆ្នាំមួយដង<br>Sports Training and Competition: Conduct football (soccer) practice for boys and girls every Saturday and organize an annual tournament.<br>5. ការបោះជំរុំយុវជនមួយឆ្នាំមួយដង<br>Youth Camp: Organize a youth camp once a year.<br>6. ការដឹកនាំយុវជនជួយការងារសហគមន៍ និងមនុស្សធម៌ និងការចូលរួមផ្សាយដំណឹងល្អ<br>Youth Leadership in Community Service and Evangelism: Engage youth leaders in community service, charitable activities, and participating in evangelism. | |
| ពង្រឹងស្ត្រីក្នុងសេចក្តីជំនឿ និងការប្រកប (១០ នាក់)<br>Strengthen Women's Faith and Fellowship (10 people) | 1. បង្កើតក្រុមស្ត្រី និងជ្រើសរើសអ្នកដឹកនាំ១-២ នាក់<br>Establish a Women's Group: Form a women's group and select 1–2 leaders.<br>2. បង្កើតថ្នាក់រៀនព្រះគម្ពីរ ថ្វាយបង្គំ ការអធិស្ឋាន ការសិក្សាព្រះគម្ពីរមួយខែមួយដង<br>Establish Bible Study Classes: Hold monthly Bible study classes including worship, prayer, and Scripture learning.<br>3. ការចុះសួរសុខទុក្ខ និងការផ្តល់អាហារលើកទឹកចិត្ត និងផ្តល់ជង្វាយស្ម័គ្រពីចិត្តចំពោះស្ត្រីដែលមានជម្ងឺ និងខ្វះខាត ដោយចុះមួយខែ១ដង<br>Visitation and Support: Conduct monthly visits to provide encouragement, food, and heartfelt assistance to women who are sick or in need. | កុម្ភៈ ២០២៦-ធ្នូ ២០៣០<br>Feb 2026-Dec 2030 |

| | | |
|---|---|---|
| | 4. អញ្ជើញវាគ្មិន ក្នុងការធ្វើសិក្ខាសាលាស្ត្រីមួយឆ្នាំ ២ ដង<br>Invite Guest Speakers: Organize women's seminars twice a year with invited speakers.<br>5. បង្កើតកម្មវិធីដំណើរកំសាន្ត ឬការប្រកបពិសេស មួយឆ្នាំមួយដង<br>Organize Special Fellowship or Trips: Create recreational trips or special events for the group  for one times/year | |
| ពង្រឹងបុរសក្នុងសេចក្តីជំនឿ និងការប្រកប (១០ នាក់)<br>Strengthen Men's Faith and Fellowship (10 people) | 1. បង្កើតក្រុមបុរស និងជ្រើសរើសអ្នកដឹកនាំ១-២ នាក់<br>Establish a Men's Group: Form a men's group and select 1–2 leaders.<br>2. បង្កើតថ្នាក់រៀនព្រះគម្ពីរ ថ្វាយបង្គំ ការអធិស្ឋាន ការសិក្សាព្រះគម្ពីរមួយខែមួយដង<br>Establish Bible Study Classes: Hold monthly Bible study classes including worship, prayer, and Scripture learning.<br>3. ការចុះសួរសុខទុក្ខ និងការប្រកបរបស់បុរស (ស្ទូចត្រី ការញាំកាហ្វេ ការលេងកីឡា) ដើម្បីបង្កើនទំនាក់ទំនង 4 ដងក្នុងមួយឆ្នាំ<br>Visitation and Men's Fellowship: Conduct home visits and organize joint activities for men (fishing, coffee gatherings, sports) to strengthen relationships  for 4times/year<br>4. បង្កើតកម្មវិធីដំណើរកំសាន្ត ឬការប្រកបពិសេស មួយឆ្នាំមួយដង<br>Organize Special Fellowship or Trips: Create recreational trips or special events for the group for one time/year. | កុម្ភៈ ២០២៦-ធ្នូ ២០៣០<br>Feb 2026-Dec 2030 |

<table>
<tr>
<td>ពង្រឹងការថ្វាយបង្គំ និងការផ្សាយដំណឹងល្អ<br>Strengthen Worship and Evangelism</td>
<td>• ព្រះវិហារនិងការថ្វាយបង្គំ<br>□□□□□□□ □□□ □□□□□□□□<br><br>1. ការបន្តបណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពគ្រូគង្វាល និងអ្នកបម្រើព្រះ ព្រមទាំងការប្រកប 3 ដងក្នុងមួយឆ្នាំ<br>Ongoing Training and Capacity Building: Continue training and strengthening the skills of pastors and church servants, along with conducting fellowship 3 times a year.<br>2. ពង្រឹងក្រុមថ្វាយបង្គំ និងចម្រៀងពិសេសដោយមានការហ្វឹកហាត់រៀងរាល់ថ្ងៃសៅរ៍<br>Strengthen Worship and Special Song: Enhance the worship and special choir team through practice every Saturday.<br>3. បណ្តុះបណ្តាលយុវជន 2-3 នាក់ក្នុងការលេងភ្លេងសម្រាប់ការថ្វាយបង្គំ<br>Train 2–3 Youth in Music: Provide training for 2–3 youth to play instruments for worship services.<br>4. បង្កើតការបោះជំរុំគ្រួសារពួកជំនុំមួយឆ្នាំម្តង<br>Organize a Family Camp: Hold a family camp once a year.<br>5. ការចុះសួរសុខទុក្ខ និងអធិស្ឋានសម្រាប់សមាជិកពួកជំនុំរៀងរាល់ថ្ងៃសៅរ៍<br>Visits and Prayer: Conduct home visits and prayer for group members every Saturday.<br><br>• ការផ្សាយដំណឹងល្អ/ □□□□□□□□□□□□<br>6. បង្កើតក្រុមផ្សាយដំណឹងល្អចំនួន៥នាក់<br>Establish an Evangelism Team: Form a team of 5 members for outreach and evangelism.<br>7. បង្កើតថ្នាក់រៀនរបៀបផ្សាយដំណឹងល្អសម្រាប់បរិបទកម្ពុជាសម្រាប់ក្រុមផ្សាយដំណឹងល្អ<br>Conduct Evangelism Training Class: Create a class on evangelism methods tailored to the Cambodian context for the evangelism team.<br>8. ការចុះផ្សព្វផ្សាយដំណឹងល្អតាមរយៈការចែកខិតប័ណ្ណផ្សាយដំណឹងល្អ និងតាមរយៈការចុះសួរសុខទុក្ខ បង្កើតទំនាក់ទំនង</td>
<td>មករា ២០២៦ - ធ្នូ ២០៣០<br>Jan 2026- Dec 2030</td>
</tr>
</table>

| | | |
|---|---|---|
| | Evangelism Outreach: Share the Good News through distributing Gospel Poster and conducting home visits to build relationships.<br>9. បង្រៀនមូលដ្ឋានព្រះគម្ពីរនិងអធិស្ឋានសម្រាប់អ្នកថ្វាយខ្លួន និងនាំគេមកចូលរួមថ្វាយបង្គំ<br>Teach basic bible and Prayer: Instruct new believer in foundational Bible knowledge and prayer, guiding them to actively participate in worship services. | |

## VII. ប្រភពធនធាន / **Resource**

- **ព្រះវិហារកោះរំដួលបាប់ទីស្ទធ្វើការជាមួយ៖**

  **Widow Island Baptist Church work with:**

  - ស្ត្រីមេម៉ាយ ក្មេងកំព្រា / Widows and orphaned children
  - កុមារ យុវជន និង ចាស់ទុំ / Children, youth, and the elderly
  - ជនដែលត្រូវបានគេរើសអើង(ជនពិការ ក្រីក្រ ជនសេពគប់គ្រឿងញៀន…ល) / Marginalized groups (people with disabilities, the poor, drug users, etc.)

- **ធនធានដែលព្រះវិហារមាន៖**

  **Church Resource:**

  - គ្រូគង្វាល១នាក់ និងគ្រូជំនួយ២ នាក់

    One pastor in charge and two assistant pastors
  - គ្រូបង្ហាត់កុមារថ្នាក់ថ្ងៃអាទិត្យចំនួន៣នាក់ គ្រូយុវជន១នាក់ គ្រូរបាំ១នាក់ គ្រូដឹងនាំក្រុមស្ត្រី ២នាក់ ក្រុមផ្សាយដំណឹងល្អមួយក្រុម

    Three Sunday school teachers for children, one youth teacher, one dance teacher, two women’s group leaders, and one evangelism team
  - មានអគ្គារថ្វាយបង្គំព្រះ១ខ្នង សាលាបង្រៀនកុមារ១ខ្នង និងសម្ភារៈប្រើប្រាស់មួយចំនួន (កង្ហារ ម៉ាសិនត្រជាក់ ហ្គីតា ព្យាណូ តុ កៅអី សៀវភៅបង្រៀនព្រះបន្ទូលព្រះ ព្រះគម្ពីរ និង សៀវភៅចម្រៀង)។

    One main worship hall, one classroom for teaching children, and various materials (fans, air conditioner, guitar, piano, tables, chairs, teaching books, Bibles, and songbooks)

## VIII. បណ្តាញដៃគូរសហការណ៍ / **Partnership**

ព្រះវិហារកោះរំដួលបាប់ទីស្ទមានចំណងមិត្តភាពនិងធ្វើការសហការណ៍ក្នុងបេសកកម្មផ្សាយដំណឹងល្អព្រះជាមួយៈ

Widow Island Baptist Church has friendships and collaborates in the mission of spreading the Good News of Jesus Christ with:

- ព្រះវិហារសិរីភាពបាប់ទីស្ទ/ Liberty Baptist Church
- អង្គការផ្តល់ការជូរដល់កុមារ/ Operation Christmas Child (OCC)
- បេសកជននៅវៀតណាម និងអាមេរិក/ Missionary in Vietnam and America
- ព្រះវិហារនៅសិង្ហបុរី និងហ្វីលីពីន/ Church in Singapore and Philippine

## IX. វិសោធនកម្ម/ **Amendments**

ផែនការយុទ្ធសាស្ត្រនេះនឹងត្រូវលុបចោល កែប្រែ ឬធ្វើវិសោធនកម្ម ដោយមានការជូនដំណឹង៣ខែមុន និងធ្វើឡើងដោយមានការបោះឆ្នោតគាំទ្រពីមតិភាគច្រើន ឬ២ភាគ៣នៃសមាជិកទាំងអស់នៃព្រះវិហារ។

This Strategy Plan may be repealed, altered, or amended by three-months prior notification and then a 2/3 majority vote of church members.

### ផ្នែកទី១៖ អាសយដ្ឋានចុះបញ្ជី

□□□□ 1: □□□□□□□□□□ □□□□□□□

**ព្រះវិហារមានអាសយដ្ឋាន៖** ភូមិកោះរំដួល សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្តាល

**ហ្វេសបុកព្រះវិហារ៖** Baptist Church Widow Island

**មនុស្សទំនាក់ទំនង៖** លោកគ្រូ រស់ ចាន់មករា លេខទូរស័ព្ទ៖ +855 96 218 7546

អ៊ីម៉ែល៖ mrusechan@gmail.com

**Address of the church:** Romdoul Village, Rokah Kpos Commune, Ta Kmao Town, Kandal Province

**Church Facebook Page:** Baptist Church Widow Island

**Contact Person:** Ps. Ruse Chan Makara, Tel: +855 96 218 7546,

Email: mrusechan@gmail.com